## ២- សេចក្តីសំរេច

ធ្វើនៅភ្នំពេញ,ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៦២ សសរ
### ស្តីពី
### ការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាល

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញ ទៅចូលរួមកិច្ចប្រជុំកំពូលអាស៊ាន ក្រៅផ្លូវការ លើកទី៤ ចាប់ពីថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ ២០០០ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត ក្រុង និងឯកឧត្តម ស ខេង ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

ធ្វើនៅភ្នំពេញ,ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ ២០០០

### សេចក្តីសំរេច លេខ ៦៣ សសរ.ធអ
### ស្តីពី ការតែងតាំងគណៈកម្មការរុករក គាស់ និងធ្វើមាតុភូមិនិវត្តន៍នូវអដ្ឋិធាតុកងទ័ពសហរដ្ឋអាមេរិក ដែលបាត់ខ្លួន ដែលបានពលីជីវិត កាលពីសង្គ្រាម នៅកម្ពុជា

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងស្មារតីនៃកិច្ចព្រមព្រៀង ចុះថ្ងៃទី២៨ ខែ សីហា ឆ្នាំ ២០០០ នៅភ្នំពេញ រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការរុករក ការគាស់ និងការធ្វើមាតុភូមិនិវត្តន៍ នៃអដ្ឋិធាតុកងទ័ពស្ម័គ្រចិត្តវៀតណាម ដែលបានពលីជីវិត កាលពីសង្គ្រាមនៅកម្ពុជា ។

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការរុករក គាស់ និងធ្វើមាតុភូមិនិវត្តន៍ នូវអដ្ឋិធាតុកងទ័ពស្ម័គ្រចិត្តវៀតណាម ដែលបានពលីជីវិត កាលពីសង្គ្រាមនៅកម្ពុជា ដែលមានសមាសភាពរួមមាន :

| | | |
|---|---|---|
| - ឯកឧត្តម ឧត្តមសេនីយ៍ ម៉ុល សារឿន | អគ្គមេបញ្ជាការរងនិងជានាយសេនាធិការចំរុះនៃកងយោធពលខេមរភូមិន្ទ | ប្រធាន |
| - ឯកឧត្តម សៀង ឡាប្រេស្ស | អនុរដ្ឋលេខាធិការក្រសួងការបរទេស | អនុប្រធាន |
| - លោក ជ័យ សាផុន | ប្រធានគណៈកម្មការស្រាវជ្រាវប្រវត្តិសាស្ត្របក្ស | អនុប្រធាន |
| - លោក ជុំ សូយ៉ាត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| - ឯកឧត្តម | អភិបាលខេត្ត-ក្រុង | សមាជិក |
| - លោក គឹម ចាន់នី | ប្រធានការិយាល័យ (អាំងទែរប៉ូល) ក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាង | នាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គមេបញ្ជាការ ខ.ភ.ម. | សមាជិក |
| - តំណាង | កងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - តំណាង | ក្រសួងសុខាភិបាល | សមាជិក |
| - តំណាង | ក្រសួងបរិស្ថាន | សមាជិក |
| - តំណាង | នាយកដ្ឋានអាស៊ី ក្រសួងការបរទេស | សមាជិក |

**ប្រការ២ :** សមាជិកនៃគណកម្មការនេះ ត្រូវចូលរួមប្រជុំ តាមការកោះអញ្ជើញរបស់ប្រធានគណកម្មការ ។

**ប្រការ ៣ :** គណកម្មការរុករក គាស់ និងធ្វើមាតុភូមិនិវត្តន៍នូវអដ្ឋិធាតុកងទ័ពស្ម័គ្រចិត្តវៀតណាម ដែលបានពលីជីវិត កាលពីសង្គ្រាម នៅកម្ពុជា មានភារកិច្ច :

-ស្រាវជ្រាវរុករកអដ្ឋិធាតុទាហានវៀតណាម ដែលបានពលីជីវិតក្នុងពេលសកម្មភាពសង្គ្រាមនៅកម្ពុជា ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ខេត្ត ក្រុង ដែលមានការពាក់ព័ន្ធ និងត្រូវសហការជាមួយគណៈកម្មការខាងភាគីវៀតណាម ដើម្បីអនុវត្តការងារអោយបានល្អ តាមស្មារតីនៃកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរ ។

-ទទួលខុសត្រូវរួមជាមួយគណៈកម្មការខាងវៀតណាម ចំពោះការត្រួតពិនិត្យនិងសំរបសំរួលគ្រប់សកម្មភាពទាំងអស់ ដែលទាក់ទងនឹងការអនុវត្តកិច្ចព្រមព្រៀង ហើយរាយការណ៍ជូនរដ្ឋាភិបាលនៃប្រទេសទាំងពីរ ។

-ជួបជុំនិងពិភាក្សាគ្នាជាមួយគណៈកម្មការខាងវៀតណាម ដើម្បីចុះហត្ថលេខាលើការព្រមព្រៀងជាក់ស្តែងមួយ ស្តីពីការអនុវត្តន៏កិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរ ។

-ជូនព័ត៌មានអោយគ្នាទៅវិញទៅមក តាមរយៈការទូត អំពីការអនុវត្តន៏ និងដោះស្រាយការលំបាកទាំងឡាយដែលកើតឡើងអោយបានទាន់ពេលវេលា ក្នុងដំណើរការអនុវត្តកិច្ចព្រមព្រៀង ហើយភាគីទាំងពីរជួបជុំគ្នាមួយឆ្នាំម្តង ដើម្បីសរុបការងារប្រចាំឆ្នាំ និងកំណត់ផែនការការងារសំរាប់ឆ្នាំខាងមុខ ។

ប្រការ៤ : គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រា ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាផ្លូវការ ។

ប្រការ ៥ : គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវចាត់តាំងនិងបញ្ជូនឈ្មោះមន្ត្រីតំណាងក្រសួងឬស្ថាប័នរបស់ខ្លួន ដូចមានចែងក្នុងប្រការ១ ទៅប្រធានគណៈកម្មការរុករក គាស់ និងធ្វើមាតុភូមិនិវត្តន៏ អដ្ឋិធាតុកងទ័ពស្ម័គ្រចិត្តវៀតណាម ដែលបានពលីជីវិតកាលពីសង្គ្រាមនៅកម្ពុជា ដើម្បីប្រតិបត្តិតាមមុខងារ និងតួនាទីរបស់ខ្លួនអោយមានប្រសិទ្ធភាព តាមស្មារតីនៃសេចក្តីសំរេចនេះ ។

ប្រការ ៦ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ប្រធានគណៈកម្មការ POW/MIA កម្ពុជា អភិបាលខេត្ត ក្រុង រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★